ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



ក
ស
វ

Work Activities

ប្រចាំខែមករា ឆ្នាំ២០១៨



# មាតិកា

**ល.រ** **បរិយាយ** **លេខទំព័រ**


I- កិច្ចប្រជុំជំនាញបច្ចេកទេស

១- សេចក្តីព្រាងសេចក្តីច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១-៣

២- សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះលើកកម្ពស់កិច្ចសហប្រតិបត្តិការ កម្ពុជា-បង់ក្លាដែស ៤

II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៧ ៥-១២

III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៨ ១៣-១៥

# ១-សេចក្តីព្រាងសេចក្តីច្បាប់ស្តីពី

## វិសោធនកម្មច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល



កាលពីថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **លី គឹមសុខ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងសេចក្តីច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋាន**អាកាសចរស៊ីវិល** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

យោងតាមច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវបានបង្កើតឡើងចំណុះឲ្យទីស្តីការគណៈរដ្ឋមន្ត្រីក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី និងដឹកនាំដោយអនុរដ្ឋលេខាធិការមួយរូប។

ក្នុងការដឹកនាំនិងគ្រប់គ្រងលើវិស័យអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាកន្លងមក រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានធ្វើឲ្យវិស័យអាកាសចរកម្ពុជាមានការរីកចម្រើនជាលំដាប់ ពីមួយឆ្នាំទៅមួយឆ្នាំ។ ជាងនេះទៀត ក្នុងនាមជាសមាជិករបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ(ICAO) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានទទួលលទ្ធផលជាវិជ្ជមាន។ តែទោះជាយ៉ាងក្តី ការធ្វើសវនកម្មថ្មីៗកាលពីចុងឆ្នាំ២០១៦ កន្លងទៅនេះ បានបង្ហាញថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា៖

-ការគ្រប់គ្រងផ្នែកអាជ្ញាប័ណ្ណបុគ្គលិកនៅមានភាពច្របូកច្របល់ ការគ្រប់គ្រងផ្នែក ត្រួតពិនិត្យសុវត្ថិភាព នៅមិនទាន់ឆ្លើយតបទៅនឹងទំហំការងារនិងស្តង់ដាបច្ចេកទេសនៅឡើយ។




-ការងារគ្រប់គ្រង និងដឹកនាំរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលជាក់ស្តែងដឹកនាំដោយរដ្ឋលេខាធិការ ជាប្រធានស្ថាប័ន និងតម្រូវឲ្យមានការផ្តល់សិទ្ធិជូនប្រធានស្ថាប័នអាកាសចរស៊ីវិលក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង ចាត់តាំង និងអនុម័តលើរាល់លិខិតបទដ្ឋានគតិយុត្តបច្ចេកទេស ស្តីពីអាកាសចរស៊ីវិល ប៉ុន្តែបើយោងតាមច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ឆ្នាំ១៩៩៦ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដឹកនាំដោយអនុរដ្ឋលេខាធិការមួយរូប និងស្ថិតក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី មិនមែនជារដ្ឋលេខាធិការដ្ឋានស្វយ័តទេ ទោះបីជាក់ស្តែង តាំងពីរាជរដ្ឋាភិបាលនីតិកាលទី២ មក រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដឹកនាំដោយរដ្ឋលេខាធិការ រួចហើយក៏ដោយ។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រុមការងារច្បាប់នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលយល់ឃើញថា ដើម្បីឲ្យស្របនឹងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ១៩៩៤ និងដើម្បីឆ្លើយតបទៅនឹងស្តង់ដា និងបទដ្ឋានគតិយុត្តអន្តរជាតិ ចាំបាច់ត្រូវស្នើសុំធ្វើវិសោធនកម្មមាត្រា១ និងមាត្រា៣ នៃច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

ក្នុងករណីនេះ អង្គការ ICAO តម្រូវឲ្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កែសម្រួលជាបន្ទាន់ នូវរចនាសម្ព័ន្ធគ្រប់គ្រង និងឯកសារបទដ្ឋានគតិយុត្តគ្រប់គ្រងអាកាសចរស៊ីវិល ដើម្បីឲ្យស្របតាមស្តង់ដា និងបទដ្ឋានគតិយុត្តអន្តរជាតិ បើពុំសោធទេ យើងនឹងជួបបញ្ហាប្រឈមខ្លាំងដែលអាចដាក់បញ្ចូលអាកាសចរស៊ីវិលកម្ពុជាទៅក្នុងបញ្ជីខ្មៅ(Black List) របស់អង្គការ ICAO ដែលគ្រោងនឹងចុះមកធ្វើសវនកម្មសុវត្ថិភាពអាកាសចរម្តងទៀត នៅថ្ងៃទី១០-២០ ខែធ្នូ ឆ្នាំ២០១៨ ខាងមុខនេះ។

ដូច្នេះ ដើម្បីជៀសផុតពីបញ្ហាប្រឈមទាំងនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រង់មាត្រា១ និងមាត្រា៣[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងវិសោធនកម្មនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

# ២-សេចក្តីព្រាងសេចក្តីសម្រេចស្តីពី

## ការបង្កើតគណៈកម្មការចម្រុះលើកកម្ពស់
## កិច្ចសហប្រតិបត្តិការ កម្ពុជា-បង់ក្លាដែស

កាលពីថ្ងៃព្រហស្បតិ៍ ៣ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **លី គឹមសុខ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ផៃ លី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះលើកកម្ពស់កិច្ចសហប្រតិបត្តិការ កម្ពុជា-បង់ក្លាដែស** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

យោងតាមសេចក្តីប្រកាសរួម(Joint Communiqué) រវាងកម្ពុជា-បង់ក្លាដែស ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ក្នុងឱកាសទស្សនកិច្ចផ្លូវការរបស់លោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដែស នៅកម្ពុជា បានបញ្ជាក់ឡើងវិញអំពីការបង្កើតគណៈកម្មការចម្រុះរវាងកម្ពុជា-បង់ក្លាសដែស ដឹកនាំដោយរដ្ឋមន្ត្រីទាំងពីរ។ គណៈកម្មការចម្រុះនឹងជួបប្រជុំគ្នាលើកទី១ នៅឆ្នាំ២០១៨ នាទីក្រុងដាកាប្រទេសបង់ក្លាដែស។

គណៈកម្មការនេះមានតួនាទីនឹងភារកិច្ចដូចខាងក្រោម៖

-ពិគ្រោះយោបល់ និងសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស លើវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គម វប្បធម៌ និងវិស័យដ៏ទៃទៀត ដែលមានប្រយោជន៍ទៅវិញទៅមក

-ពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និងពិភាក្សាបញ្ហាទាំងឡាយ ដែលអាចកើមានឡើងពីការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យនានា

-ប្រជុំជាមួយគណៈកម្មការភាគីបង់ក្លាដែស តាមការព្រមព្រៀងគ្នាជាមុន ដោយឆ្លាស់វៀនគ្នាម្តងម្នាក់នៅប្រទេសបង់ក្លាដែសនិងនៅប្រទេសកម្ពុជា

-សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារ កម្មវិធីនៃសកម្មភាព ក្នុងការគ្រប់គ្រងនិងជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជានិងបង់ក្លាដែស ក្នុងទិសដៅអភិវឌ្ឍវិស័យនានាដែលបានព្រមព្រៀងគ្នា ដោយរដ្ឋាភិបាលប្រទេសទាំងពីរ

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនបករមុខរាជរដ្ឋាភិបាល (តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី) ដើម្បីសុំមតិណែនាំនិងគោលការណ៍សម្រេច

-ទទួលភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះលើកកម្ពស់កិច្ចសហប្រតិបត្តិការ កម្ពុជា-បង់ក្លាដែស។

## II- កិច្ចប្រជុំស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១៧



របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➤ អតិផរណាឆ្នាំ២០១៧ មានអត្រាស្មើនឹង២,៩% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃលើសអត្រានេះមាន ម្ហូបអាហារ ការដឹកជញ្ជូន និងភោជនីយដ្ឋាន។

តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ៖

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ ២០១៧ | អត្រារួមចំណែក | អតិផរណាឆ្នាំ ២០១៦ |
|---|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ២,៩% | ១០០% | ៣,០% |
| ១ | ម្ហូបអាហារ | ៣,៤% | ៥១% | ៥,៧% |
| ២ | ការដឹកជញ្ជូន<br>ក្នុងនោះប្រេងសាំង | ៤,១%<br>៩% | ១៧%<br>១៦% | -៧,០%<br>-១៥,០% |
| ៣ | ភោជនីយដ្ឋាន | ៦,២% | ១៣% | ៣,៩% |
| ៤ | សម្លៀកបំពាក់ និងស្បែកជើង | ២,៩% | ៣% | ៤,៤% |
| ៥ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ១,៩% | ៣% | ៩,៧% |
| ៦ | គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | ១,៣% | ១,២% | ៣,០% |
| ៧ | ការកម្សាន្ត និងវប្បធម៌ | ១,០% | ១,០% | ៣,៣% |
| ៨ | ទំនិញ និងសេវាកម្មផ្សេងៗ | ១,២% | ០,៩% | ០,៥% |
| ៩ | សុខាភិបាល | ០,៤% | ០,៨% | ២,៦% |
| ១០ | ការសិក្សា | -០,២% | -០,១% | ០,៤% |
| ១១ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងៗ | -០,២% | -១,០% | -១,២% |
| ១២ | ទូរគមនាគមន៍ | -០,៤% | -០,១% | ០,៦% |

⇨ក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះមាន ក្រុមការសិក្សា ក្រុមទូរគមនាគមន៍ និងក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងៗ។

តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ២០១៥-២០១៧(ជាកំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ខែដូចគ្នាឆ្នាំមុន | 0,៣% | 0,១% | 00%, | 0៤,% | -0២%, | 0១%, | 0៣%, | 0៤%, | 0៣%, | -0២%, | 0២%, | 0,៤% | ២,៩% |
| ២០១៦ | ខែដូចគ្នាឆ្នាំមុន | -0,២% | 0,៤% | -0,២% | ១,៤% | 0,៥% | 0,២% | 0,៣% | 0,២% | 0,៣% | 0,៤% | 0,0% | 0,៤% | ៣,0% |
| ២០១៥ | ខែដូចគ្នាឆ្នាំមុន | 0,៤% | ១,៦% | ១,១% | ១,៣% | ១,0% | 0,៧% | 0,៨% | 0,៨% | 0,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |

⇨ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ប្រេងសាំង៩% ប្រេងម៉ាស៊ូត៨% ត្រីស្រស់៦,៧% បន្លែ៤,៦% និងសាច់គោ៣,២%។

➢**អត្រាប្តូរប្រាក់**:

⇨ប្រាក់រៀលមានស្ថេរភាពធៀបនឹងប្រាក់ដុល្លារអាមេរិក និងប្រាក់ដុង ប៉ុន្តែមានការធ្លាក់ថ្លៃ១០,៧%ធៀបនឹងប្រាក់បាត។ នាចុងឆ្នាំ២០១៧ អត្រាប្តូរប្រាក់រៀល មានស្ថានភាពដូចខាងក្រោម:

- ប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានអត្រា៤០៣៧៛/ដុល្លារ
- ប្រាក់រៀលធៀបនឹងដុងវៀតណាមមានអត្រា0,១៧៨៛/ដុង
- ប្រាក់រៀលធៀបនឹងបាតថៃមានការធ្លាក់ថ្លៃ១0,៧% និងមានអត្រា១១៤៛/បាត។

## ២) ស្ថានភាពថវិកាជាតិ

➢យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១៧នេះ អនុវត្តបានចំនួន ១៦.៦៨៦,៣ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤.១៧១,៦លានដុល្លារ) ស្មើនឹង ១០៥% នៃផែនការ ក្នុងនោះចំណូលចរន្ត ១៦.២៨៦,៣ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤.០៧១,៦លានដុល្លារ) ស្មើនឹង ១០៥% នៃផែនការ និងចំណូលមូលធន៣៩៩,៨ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៩៩,៩លានដុល្លារ)។

➢ បើធៀបនឹងឆ្នាំ២០១៦ ចំណូលថវិកាជាតិកើនឡើង ១៤% ក្នុងនេះ ចំណូលចរន្តកើនឡើង១៥% និងចំណូលមូលធនថយចុះ២,0%។

⇨ ការកើនឡើងនៃចំណូលចរន្តជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង១៦% និងចំណូលមិនមែនសារពើពន្ធ កើនឡើង៩%។

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០១៦ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០១៦ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ១០៥% | +១៦% | **ចំណូលមិនមែនសារពើពន្ធ** * | ៩៤% | +៩% |
| ✓**ពន្ធ និងអាករគយ** ** | ១០៧% | +១២% | ✓កាស៊ីណូ | ៨៧% | -២៩% |
| –ពន្ធគយ (របបនាំចូល) | ៩២% | -២% | ✓ចំណូលពីអជ្ញាបណ្ណក្នុងស្រុក | ៩៣% | -២១% |
| –អាករពិសេសលើរបបនាំចូល | ១៣២% | +៣០% | ✓កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ៨៣% | -២៣% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១០១% | +៦% | ✓នេសាទ | ៨៣% | +៤៧% |
| –អាករនាំចេញ | ៩៤% | +៤៦% | ✓ រុក្ខាប្រមាញ់ | ១៣៧% | +៦០% |
| –អាករបន្ថែមលើគេលសិលា | ១០២% | +៣% | ✓សម្បទានរ៉ែ | ៦២% | -១៣% |
| ✓**ចំណូលពន្ធដារ** *** | ១១២% | +២៨% | ✓អាកាសចរណ៍ស៊ីវិល | ១០៧% | -៤% |
| –ពន្ធលើប្រាក់បៀវត្ស | ១០០% | +១១% | ✓ ផលទុនទេសចរណ៍ | ១០៤% | +៧៤% |
| – ពន្ធលើប្រាក់ចំណេញ | ១២០% | +៣២% | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៦៩% | -៩% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ១០៧% | +២៨% | ✓អាករស្នាក់នៅ | ៩៩% | +១៨% |
| – អាករលើផលរបរ | 0% | -៩៧% | ✓ ត្រួតពិនិត្យគុណភាពផលិតផល | ៧៥% | -២៩% |
| – អាករលើតម្លៃបន្ថែម | ១១៥% | +៣២% | ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | ៧៩% | -២% |
| –អាករពិសេស | ១០១% | +១៦% | | | |
| –ពន្ធថវិកាខេត្តរាជធានី | ១០៨% | +៣៣% | | | |

* តួលេខរតនាគាជាតិ  ** តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ  *** តួលេខអគ្គនាយកដ្ឋានពន្ធដារ

➢ចំណាយថវិកាជាតិក្នុងឆ្នាំ២០១៧ អនុវត្តបាន១៤.៣១៥,៩ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៣.៥៧៩,០លានដុល្លារ) ស្មើនឹង ៩០% នៃផែនការ ក្នុងនោះ ចំណាយចរន្ត ១២.០៨៧,៧ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៣.០២១,៩លានដុល្លារ) ស្មើនឹង ៩៣% នៃផែនការ និងចំណាយមូលធន ២២២៨,៣ប៊ីលានរៀល។

➢បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង ៣២%ក្នុងនោះចំណាយចរន្តកើនឡើង ១២%និងចំណាយមូលធនកើនឡើង៦%។

➢ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០១៧ មានអតិរេកចំនួន ២.៣៧០,៤ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៥៩២,៦លានដុល្លារ)។ ប៉ុន្តែគួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលបានឆ្លងកាត់រតនាគារជាតិតែប៉ុណ្ណោះ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៧មានសូចនាកររូបិយវត្ថុដូចខាងក្រោម៖

⇨រូបិយវត្ថុ *M2* មានចំនួន៧១៣១៩ប៊ីលានរៀល កើនឡើង២៣,៨% ធៀបនឹងឆ្នាំ២០១៦។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៧**(% នៃរូបិយវត្ថុទូទៅ*M2*)




**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៦**




⇨សមាសធាតុរូបិយវត្ថុមិនសូវមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ទេ : រូបិយវត្ថុក្រៅធនាគារកើនឡើងពី ១១,២% នៃM2 ក្នុងឆ្នាំ២០១៦ មក១១,៦% ក្នុងឆ្នាំ២០១៧ ឯប្រាក់បញ្ញើជារូបិយបណ្ណបរទេសថយចុះពី៨៣,២% ទៅ ៨៣,១%នៃM2។

⇨តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន (២០១៣-២០១៧)

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| *M2* | +១៥% | +២៩,៩% | +១៤,៧% | +១៧,៩% | +២៣,៨% |
| *សមាមាត្រ M2 ក្នុងផសស* | ៥៣% | ៦៣% | ៦៧% | ៧២% | ៨០% |
| *M1* | +២១% | +២៩,៣% | +៦,៩% | +៧,២% | +២៩,៦% |
| *សមាមាត្រ M1 ក្នុងផសស* | ៨% | ៩% | ៩,២% | ៩% | ១០,៥% |
| រូបិយវត្ថុក្រៅធនាគារ | +១៩% | +២៥,៦% | +៥,៤% | +៨,៩% | +២៨,២% |
| ប្រាក់បញ្ញើចរន្ត | +៤៦% | +៦៨,៥% | +១៨,១% | -៥,៣% | +៤០,៩% |
| រូបិយវត្ថុផ្សេងៗ | +១៤% | +៣០% | +១៦,១% | +១៩,៦% | +២២,៩% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +២១% | +១៥,៣% | +៤២,២% | +៥៤,០% | +៩,៦% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +១៣% | +៣០,៥% | +១៥,៣% | +១៨,៣% | +២៣,៦% |

⇨ក្នុងឆ្នាំ២០១៧ រូបិយវត្ថុទូទៅM2មានចំនួនប្រហែល ៨៦%នៃផសស ប៉ុន្តែ**សមមាត្រ***M1*ក្នុងផសស មានត្រឹមតែ ១០,៥% ប៉ុណ្ណោះ។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន៨៦៦១ លានដុល្លារកើនឡើង៣០,៥%ធៀបនឹងឆ្នាំ ២០១៦។

➢ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន២៦២៨៥ ប៊ីលានរៀលកើនឡើង ៣០,៧% បើធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន៦៨២៧១ប៊ីលានរៀលកើនឡើង ១៩,៧%ធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(មិនទាន់មានតួលេខ)

➢**អត្រាការប្រាក់ប្រចាំឆ្នាំ**:

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ ២០១៧* | *អត្រាឆ្នាំ ២០១៦* | %∆(២០១៧/២០១៦) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩% | ៦,៩១% | -១៤,៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៥% | ១៧,៣៥% | -១៦,៥% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤៤% | -០,៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦៧% | ១១,៩០% | -២,០% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៨% | ២៣,៤% | -២៣,១% |
| កម្ចីជារៀលនៅអម្រឹត | ១៨% | ២៨,៨% | -៣៧,៥% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,៥% | ២២,៨% | -២៣,២% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢***កសិកម្ម***:

⇨ផលិតផលស្រូវប្រចាំឆ្នាំ២០១៧ មានចំនួន ១០ ៣៩៨ពាន់តោន មានការកើនឡើង៤,៥%ធៀបនឹងឆ្នាំ២០១៦ ដែលមានទំហំ ៩ ៩៥២ពាន់តោន។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពី ការកើនឡើងនៃផ្ទៃដីដាំដុះ ពី ៣១១៨ពាន់ហិកតា នាឆ្នាំ២០១៦ ទៅ ៣១៨០ពាន់ហិកតា នាឆ្នាំ២០១៧ រីឯទិន្នផលស្រូវនៅស្អេរ មាន៣,១៧៨ តោន/ហិកតា។

ផលិតផលស្រូវ (ពាន់តោន)




ទិន្នផលស្រូវ (តោន/ហិកតា)




⇨ក្នុងឆ្នាំ២០១៧ ផលិតផលកៅស៊ូមានចំនួន១៩៣,៣ពាន់តោន កើនឡើង ៣៣,១% ធៀបនឹងឆ្នាំ២០១៦។ ផ្ទៃដីចៀរជ័រមានចំនួន១៧០,២ ពាន់ហិកតាកើនឡើង៣៤,០%ធៀបនឹងឆ្នាំ២០១៦ និងផ្ទៃដីដាំដុះសរុបមាន ៤៣៦,៣ ពាន់ហិចតាកើនឡើង ០,៨%ធៀបនឹងឆ្នាំ២០១៦។

⇨ ផលិតកម្មនេសាទឆ្នាំ២០១៧ មានចំនួន ៨៥៦,៣ ពាន់តោនមានការកើនឡើង ៧%ធៀបនឹងឆ្នាំ២០១៦។

➢***ឧស្សាហកម្ម***

⇨ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន៧០១៩,៥លានដុល្លារកើនឡើង៣%។

⇨ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន ២៧៧លានម៣កើនឡើង១៦%។

⇨ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន១៥២២រោងចក្រ ថយចុះ៤,០% ធៀបនឹងឆ្នាំ២០១៦។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម:**

| *ប្រភេទ* | *ចំនួន :២០១៧* | *ចំនួន:២០១៦* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១៥២២ | ១៥៧៩ | -៤,០% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៥០ | ១៤១ | +៦,០% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៤៩ | ១២៥ | +៩៩% |
| ឧស្សាហកម្មធនតូច និងសិប្បកម្ម (បន្ត) | ៤២១ | ១៦៩ | +១៤៩% |

➢ ***រ៉ែនិងថាមពល:***

ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៧៧៨២,៥ GWh កើនឡើង ១៦% ។ ក្នុងនោះ វារីអគ្គិសនីមានចំនួន២៧០៣,៩ GWh កើនឡើង ៦% ធ្យូងថ្មចំនួន៣៥៧២,៧GWh កើនឡើង ៤៩% នាំចូលពីប្រទេសជិតខាងចំនួន១១៥៧,៥ GWh ថយចុះ១៤%ធៀបនឹងឆ្នាំ២០១៦។

➢**សំណង់ (ការអនុញ្ញាត):**

▪ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១៧ មានចំនួន១១៣៨១,៩ពាន់ម២ ថយចុះ៦%បើគិតជាទឹកប្រាក់ស្មើនឹង ៦៧៩៨,៧លានដុល្លារកើនឡើង២២% ធៀបនឹងឆ្នាំ ២០១៦។

| *ប្រភេទសំណង់* | ពាន់ម២ :២០១៧ | ពាន់ម២ :២០១៦ | % ∆ |
|---|---|---|---|
| លំនៅឋាន | ៥៨០៤,៤ | ៦៣២១,៦ | -៨,០% |
| ឧស្សាហកម្ម | ១១៩៥,១ | ២២៣៩,៦ | -៤៧% |
| ពាណិជ្ជកម្ម | ៣៧៦៣,៧ | ៥៦០៣,៦ | -៣៣% |
| ទេសចរណ៍ | ៥៦១,៨ | ៣៨៤,៥ | +៤៦% |
| ... | | ... | ... |
| អនុញ្ញាតសរុប | ១១៣៨១,៩ | ១២១៥៨ | -៤,០% |

▪ ក្នុងការអនុញ្ញាតនេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (៥១%នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (៣៣% នៃផ្ទៃក្រឡាសរុប) ។

▪**ការងារ:**

| *ប្រភេទ* | ២០១៧ (នាក់) | ២០១៦ (នាក់) | %∆ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារជាតិមុខរបរ និងការងារ) | ១៥១៣២ | ១៣៦១៨ | +១១% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៨២៨៩៦ | ១៣៩៧៥៤ | +៣១% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៥១៩៤៩ | ១១២៥១០ | +៣៥% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៤១០៣ | ២៧២៤២ | +៦២% |

**▪វិនិយោគ:** *គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. ក្នុងឆ្នាំ២០១៧*

| ប្រភេទ | ២០១៧ | ២០១៦ | %Δ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៦៣៣១,១ | ៣៦០៩,៦ | +៧៥% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣៩៦,២ | ៤៧៨,៣ | -១៧% |
| វិស័យឧស្សាហកម្ម | ១២៦៨,៩ | ១១៨៦,៣ | +៧% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ៤៨៤,០ | ២៨៣,៣ | +៧១% |
| វិស័យទេសចរណ៍ | ៣១៦៦,៦ | ១៤០០,៨ | ១២៦% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៤៩៩,៥ | ៥៤៤,៣ | +១៧៥% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ១៨៣ | ១៧១ | +៧% |
| **ចំនួនពលករ (ពាន់នាក់)** | ២០១,៣ | ១៦៤,៧ | +២២% |

**▪សេវាកម្មនិងទេសចរណ៍:**

**➢ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| ប្រភេទ | ២០១៧ (ចំនួន) | ២០១៦(ចំនួន) | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | ៤៣៨៩ | |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | ៦ | |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៥៦៦៥ | ៥២៥៧ | +៨% |

**➢ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ)មានចំនួន ១០១១៨,៨ពាន់តោនកើនឡើង១៦%។ ក្នុងនោះ:

| ប្រភេទ | ២០១៧ (ពាន់តោន) | ២០១៦(ពាន់តោន) | %Δ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ២៧៦០,៩ | ២៤៥៥ | +១២% |
| កំពង់ផែកំពង់សោម | ៦៤៦១,២ | ៥៣១៦,១ | +២២% |
| កំពង់ផែស្រែអំបិល និងកោះកុង | ១៩៩,៤ | ៣១៩,១ | -៣៩% |
| កំពង់ផែឧកញ៉ាម៉ុង | ៧៣៤,៤ | ៦៣៦,៣ | +១៥% |

**➢ប្រៃសណីយ៍និងទូរគមនាគមន៍**

| ប្រភេទ | ២០១៧ | ២០១៦ | %Δ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២០៤,៣ | ១៧៤,៥ | +១៧% |
| ក្នុងនោះទទួល | ២៨ | ២៦,៤ | +៦,២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១២៤៥,៤ | ១២២៧,៤ | +១,៥% |
| ក្នុងនោះទទួល | ៦៥១ | ៥៧៨,៧ | +១២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៧៧១៤,៩ | ៣៣១៩១,០ | -១៦% |
| ក្នុងនោះហៅចូល | ៨១៧០,៤ | ៩៨៤៥,៧ | -១៧% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១០៦៦៧២,៦ | ១២២២៤៥,១ | -១៣% |
| ក្នុងនោះហៅចូល | ១០៥៨៣០ | ១២១៤៤៣,០ | -១៣% |

➢អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| *ប្រភេទ* | ២០១៧ (ពាន់នាក់) | ២០១៦(ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២២៣,៧ | ១៨៣,៦ | +២២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៥៧១,៧ | ៤២៣,៥ | +៣៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៧៦៦៥,៧ | ៦២០១,៣ | +២៤% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ១៧៥២,៣ | ១៤៣៤ | +២២% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៥៦០១,៩ | ៥០១១,៧ | +១២% |
| ✓តាមផ្លូវអាកាស | ៣៣១២,៧ | ២៧០៤,៤ | +២២% |
| ✓ តាមផ្លូវគោក និងទឹក | ២២៨៩,១ | ២៣០៧,៧ | -១,០% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១៧ មានចំនួន៥៥២៤៣,៧ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១៣.៨១០,៩លានដុល្លារ)កើនឡើង ៦% បើធៀបនឹងឆ្នាំ ២០១៦ក្នុងនោះ ៖

| មានការថយចុះ | មានការកើនឡើង |
|---|---|
| ប្រេងខ្មៅ -៣៨% | ប្រេងសាំង +១៤% |
| រថយន្តដឹកជញ្ជូន(ជាគ្រឿង) -១៦% | ប្រេងម៉ាស៊ូត +៤% |
| ម៉ូតូ -៣% | ប្រេងសាំងយន្តហោះ +៣២% |
| ស្រូវសាលី -១៩% | ឧស្ម័ន +១៦% |
| អង្ករ-៧៥% | ដែកសំណង់+៥% |
| ជី និងថ្នាំកសិកម្ម-១០% | ស៊ីម៉ង់ +៦% |
| បារី -៥% | គ្រឿងអេឡិចត្រូនិច+៣១% |
| ការនាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម -៣១% | រថយន្តទេសចរ+១៦% |
| | ត្រាក់ទ័រនិងគោយន្ត+១២% |
| | ផ្លែឈើនិងបន្លែ +១៦% |
| | សំលៀកបំពាក់ចាស់+៩% |
| | ស្ករស+៧% |
| | ភេសជ្ជៈ+៣៤% |
| | ប្រេងឆា+៣៣% |
| | ប៊ីចេង+១១% |
| | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +៣% |
| | អនុញ្ញាតិនាំចូលក្នុងក្របខ័ណ្ឌវិនិយោគឯកជន+៩% |
| | អនុញ្ញាតិនាំចូលក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈ+៣៤% |

▪**ការនាំចេញ**ឆ្នាំ២០១៧មានចំនួន៤៦១១១ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១១៥២៧,៧លានដុល្លារ) ស្មើនឹង ៨៣,៥%នៃការនាំចូល មានការកើនឡើង១៣%ធៀបនឹងឆ្នាំ២០១៦ក្នុងនោះ ៖

| ទំនិញ | %Δ ធៀបនឹង-២០១៦ | ទំនិញ | %Δ ធៀបនឹង-២០១៦ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៧៩% | ផលិតផលនេសាទ | +១០៤% |
| វាយនភណ្ឌនិងស្បែកជើង | +៧% | កៅស៊ូ | +២៥% |
| អង្ករ | -៤៧% | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | បម្រែបម្រួលធៀបនឹងឆ្នាំ ២០១៦ | ផ្សេងៗ |
|---|---|---|
| ១. ថ្លៃប្រេងសាំង | +៩% | |
| ២. ថ្លៃប្រេងម៉ាស៊ូត | +៨% | |
| ៣. ថ្លៃត្រីស្រស់ | +៦,៧% | |
| ៤. ថ្លៃបន្លែ | +៤,៦% | |
| ៥.ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម | -៤% | |
| ៦. ការអនុញ្ញាតឲ្យសាងសង់(គិតជាផ្ទៃក្រឡា) | -៦% | |

## ៧) សេចក្តីសន្និដ្ឋាន

១) ជារួមអត្រាអតិផរណាឆ្នាំ២០១៧ មានកម្រិតទាប ២,៩% ក្នុងនោះ ក្រុមម្ហូបអាហារមានការឡើងថ្លៃសរុប ៣,៤% ដែលមានកម្រិតទាបជាងឆ្នាំមុនៗ (ឆ្នាំ២០១៦ អត្រាអតិផរណានៃក្រុមម្ហូបអាហារ ស្មើនឹង ៥,៧%) ប៉ុន្តែមុខទំនិញមួយចំនួនក្រុមម្ហូបអាហារ ដូចជា បន្លែនិងត្រីស្រស់នៅតែមានការឡើងថ្លៃគួរឲ្យចាប់អារម្មណ៍។

២) ប្រេងសាំងនិងប្រេងម៉ាស៊ូតមានការឡើងថ្លៃខ្ពស់ជាងឆ្នាំ២០១៦(សាំង៩% និងម៉ាស៊ូត៨%)។ និន្នាការឡើងថ្លៃនៃឥន្ធនៈ ដែលជាធាតុចូលនៃការដឹកជញ្ជូន និងផលិតកម្ម ជាបញ្ហាប្រឈមមួយនៃសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០១៨។

៣) ការនាំជ្រូកពីប្រទេសជិតខាង ធ្វើឲ្យមានបញ្ហាចម្បងពីរ : (១) អ្នកចិញ្ចឹមជ្រូកក្នុងស្រុកអត់ទីផ្សារ វិស័យចិញ្ចឹមជ្រូកក្នុងស្រុកទាំងមូល រងហានិភ័យនៃការឈប់ចិញ្ចឹម និង (២) ដោយការនាំចូល មិនមានការគ្រប់គ្រងល្អ សត្វជ្រូកមានជំងឺ ឬជ្រូកចិញ្ចឹមដោយប្រើថ្នាំគីមីលើសកម្រិត ត្រូវបានដឹកមកស្រុកខ្មែរ លក់តម្លៃថោក បង្ខូចថ្លៃទីផ្សារ និងប៉ះពាល់សុខភាពមនុស្ស។

ជាដំណោះស្រាយ គួរតែមាន ការលើកស្ទួយការចិញ្ចឹមជ្រូកក្នុងស្រុក រកវិធីកាត់បន្ថយថ្លៃដើម និងជំរុញឲ្យមានការគាំទ្របំផុសការប្រើប្រាស់ផលិតផលជ្រូកក្នុងស្រុក។

៤) ការអនុញ្ញាតិឲ្យសាងសង់ជាផ្ទៃក្រឡាមានការថយចុះ៦% ដោយសារការថយចុះនៃសំណង់សាធារណៈ លំនៅឋាន ឧស្សាហកម្ម និងពាណិជ្ជកម្ម ប៉ុន្តែសំណង់ទេសចរមានការកើនឡើង។

៥) ជារួម ទោះជាស្ថិតក្នុងស្ថានភាពនយោបាយមិនសូវអំណោយផល ក៏សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៧ សម្រេចបានលទ្ធផលជាវិជ្ជមានរួមមាន ការផ្តល់ឥណទាន ផលិតកម្មនិងការនាំចេញវាយនភណ្ឌនិងស្បែកជើង និងទេសចរណ៍ បានបង្ហាញអំពីកំណើនធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៦។

សរុបសេចក្តីមក សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដូចជា ការឡើងថ្លៃនៃឥន្ធនៈ ការពឹងផ្អែកលើការនាំចូល ជាពិសេសម្ហូបអាហារ បន្លែ ផ្លែឈើ និងផលិតផលសាច់ ការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើងទោះមានកំណើនប៉ុន្តែមានកម្រិតទាប និងការនាំចេញអង្ករពុំទាន់សម្រេចបានតាមផែនការ៕

## III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០១/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅតំបន់ទួលសង្កែ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។ |
| ២ | ០៤/០១/១៨ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ |
| ៣ | ០៧/០១/១៨ ម៉ោង០៦:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមីទិ្ទញអបអរសាទរខួបលើកទី ៣៩ ទិវាជ័យជម្នះ ៧ មករា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័ណ៌កោះពេជ្រ។ |
| ៤ | ០៨/០១/១៨ ម៉ោង១០:៣០នាទី | អម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធសពបិតាក្មេក សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅគេហដ្ឋាននៃសព។ |
| ៥ | ០៩/០១/១៨ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសចូលកាន់តំណែង អនុប្រធានទី១ អគ្គលេខាធិការ និងអគ្គលេខាធិការរង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសាមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១០/០១/១៨ ម៉ោង០៨:៣០នាទី | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលរំលឹកខួបអនុស្សាវរីយ៍លើកទី ៣៩ ទិវាជ័យជម្នះ ៧ មករា (០៧/០១/១៩៧៩-០៧/០១/២០១៨) នៅសាលប្រជុំរដ្ឋបាលស្រុកព្រៃកប្បាស នៃខេត្តតាកែវ។ |
| ៧ | ១០/០១/១៨ ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥។<br>២-របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២១ និងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១២/០១/១៨<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥។<br>២-របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២១ និងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖ កិច្ចព្រមព្រៀងស្តីពីការជំរុញនិងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | ១៥/០១/១៨<br>**ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារមជ្ឈមណ្ឌលជាតិជំងឺមហារីក និងសម្ភពថ្មី "**អគារតេជោសន្តិភាព**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមន្ទីរពេទ្យកាល់ម៉ែត។ |
| ១០ | ១៦/០១/១៨<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារជាមួយក្រុមប្រឹក្សាអ្នកច្បាប់ដឹកនាំដោយឯកឧត្តម **ឡាំ ជា** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៧/០១/១៨<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតនៅតំបន់ព្រៃទា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិក្បាលដំរី២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |
| ១២ | ១៨/០១/១៨<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៣ | ១៩-២០/០១/១៨<br>**ពេញមួយថ្ងៃ** | ចូលរួមមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេស របស់គណបក្សប្រជាជនកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៤ | ២១/០១/១៨<br>**ម៉ោង០៧:៣០នាទី** | បន្តចូលរួមមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្សប្រជាជនកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១៥ | ២១/០១/១៨<br>ម៉ោង១៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជួបជុំរវាងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអ្នកសារព័ត៌មានក្នុងស្រុកលើកទី២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័ណ៌កោះពេជ្រ។ |
| ១៦ | ២២/០១/១៨<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកវេទិកាស្រូវអង្ករកម្ពុជាលើកទី៦ ក្រោមអធិបតីភាពឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភូគីត្រា ភ្នំពេញ។ |
| ១៧ | ២៥/០១/១៨<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាទបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិលឆ្នាំ២០១៣-២០១៧ និងលើកទិសដៅ ឆ្នាំ២០១៨-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១៨ | ២៥/០១/១៨<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែធ្នូ ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ៣០/០១/១៨<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្តីពីការបែងចែកបន្ទប់ធ្វើការ និងណែនាំការងារមួយចំនួន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in